- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ក្រឹត្យលេខ ១០ក្រ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១០/៤៦៤ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១.- ដាក់ឱ្យចូលនិវត្តន៍នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ២០រូបៈ

| | | | | | |
|---|---|---|---|---|---|
| ១- | ឧត្តមសេនីយ៍ឯក | សោម | ច័ន្ទឌីណា | អត្តលេខ | ៧៨៤៨៥ |
| ២- | ឧត្តមសេនីយ៍ឯក | អ៊ុំ | ប៊ុនថន | អត្តលេខ | ០១២៨០ |

| | | | | | |
|---|---|---|---|---|---|
| ៣- | ឧត្តមសេនីយ៍ឯក | គាំ | សារឿន | អត្តលេខ | ១៥១៧០ |
| ៤- | ឧត្តមសេនីយ៍ឯក | ហុក | ថាវណ្ណា | អត្តលេខ | ០៦៦៧ |
| ៥- | ឧត្តមសេនីយ៍ទោ | នុត | ម៉ុនធឿន | អត្តលេខ | ០៤៩០៦ |
| ៦- | ឧត្តមសេនីយ៍ទោ | ម៉ិះ | វ៉ាន់ | អត្តលេខ | ០៥៤១៣ |
| ៧- | ឧត្តមសេនីយ៍ទោ | ហាឡ្យ | ធី | អត្តលេខ | ០៥៨៤១ |
| ៨- | ឧត្តមសេនីយ៍ទោ | អឿ | សុភាព | អត្តលេខ | ០៥៨៧៩ |
| ៩- | ឧត្តមសេនីយ៍ទោ | លី | សុទិដ្ឋ័យ | អត្តលេខ | ០៧៥៩៩ |
| ១០- | ឧត្តមសេនីយ៍ទោ | គួច | ម៉ុណ្ណារី | អត្តលេខ | ២០៤២៤ |
| ១១- | ឧត្តមសេនីយ៍ទោ | ពិន | សុផល | អត្តលេខ | ៣៣៨១៩ |
| ១២- | ឧត្តមសេនីយ៍ទោ | គួច | ពិដោរឡា | អត្តលេខ | ៣៤០៨៣ |
| ១៣- | ឧត្តមសេនីយ៍ត្រី | ឌុល | សារឿន | អត្តលេខ | ០៣៧១៦ |
| ១៤- | ឧត្តមសេនីយ៍ត្រី | សៅ | សំអឿន | អត្តលេខ | ០៤៣៤៨ |
| ១៥- | ឧត្តមសេនីយ៍ត្រី | ហុង | សាវ៉ាន់ | អត្តលេខ | ០៥៨៣៨ |
| ១៦- | ឧត្តមសេនីយ៍ត្រី | ឈិន | មុន្នីភា | អត្តលេខ | ០៦៧២០ |
| ១៧- | ឧត្តមសេនីយ៍ត្រី | សាត់ | សាន្ត | អត្តលេខ | ០៧៣៥២ |
| ១៨- | ឧត្តមសេនីយ៍ត្រី | ឱក | សត្យា | អត្តលេខ | ០៧៤៨៩ |
| ១៩- | ឧត្តមសេនីយ៍ត្រី | អៀរ | ម៉ុនធឿន | អត្តលេខ | ០៨៩៩៣ |
| ២០- | ឧត្តមសេនីយ៍ត្រី | នៅ | ហាច | អត្តលេខ | ១១២៥៩។ |

មាត្រា២ : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ៕

នស/រកត . ២៥០៤ . ៥១១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០២៥*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**វង្សី វិស្សុត**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៨ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៤/០០៨ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៩១ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូក និងតាមកម្មវិធីនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ក្នុងជំពូក២១ (គម្រោងវិនិយោគផ្ទាល់) ចំនួន ៤៤០ ៣០៨លានរៀល ពីខ្ទង់ឥណទានថវិកាមិនទាន់បែងចែកអចលកម្មបីជូនក្រសួងចំនួន ៤ ដូចខាងក្រោម៖

| | |
|---|---|
| - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ចំនួន ២៣ ១៨៥លានរៀល |
| - ក្រសួងអភិវឌ្ឍន៍ជនបទ | ចំនួន ៣១៨ ៣២៣លានរៀល |
| - ក្រសួងសាធារណការនិងដឹកជញ្ជូន | ចំនួន ៣៨ ៨០០លានរៀល |
| - ក្រសួងធនធានទឹកនិងឧតុនិយម | ចំនួន ៦០ ០០០លានរៀល។ |

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៩.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៤០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-** គោលបំណង

អនុក្រឹត្យនេះមានគោលបំណងផ្តល់ការលើកទឹកចិត្តពន្ធដារ ដើម្បីអភិវឌ្ឍវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីប្រភេទ សកម្មភាព និងលក្ខខណ្ឌនានា ដែលជាកម្មវត្ថុនៃការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដូចមានចែងក្នុងមាត្រា១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩។

**មាត្រា២.-** វិសាលភាព

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះ៖

១-ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា (សរសេរកាត់ថា **ន.ម.ក.**) និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។

២-មូលបត្ររដ្ឋ ដែលសំដៅដល់បណ្ណ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុលដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល ដូចដែលបានបញ្ញត្តនៅក្នុងមាត្រា៣ នៃច្បាប់ស្តីពីមូលបត្ររដ្ឋ។

៣-អ្នកវិនិយោគសាធារណៈ ដែលកាន់កាប់ និង/ឬ ទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលដែលបានបោះផ្សាយលក់ជាសាធារណៈ និងបានចុះបញ្ជីនៅទីផ្សារមូលបត្រប្រតិស្រុត។ សម្រាប់គោលដៅនៃអនុក្រឹត្យនេះ អ្នកវិនិយោគសាធារណៈរួមបញ្ចូលទាំងអ្នកវិនិយោគនិវាសនជននិងអនិវាសនជន។



៥

## ជំពូកទី២
## សកម្មភាព និងលក្ខខណ្ឌនៃការលើកទឹកចិត្តពន្ធដារ

**មាត្រា៣.-** ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ

ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបំពេញបែបបទជូនអគ្គនាយកដ្ឋានពន្ធដារតាមរយៈ **ន.ម.ក.** នៅពេលមុនការិយបរិច្ឆេទបង់ពន្ធសម្រាប់ឆ្នាំសារពើពន្ធនីមួយៗដើម្បីទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូលតាមលក្ខខណ្ឌដូចមានកំណត់ក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ ក្នុងរយៈពេលនៃការទទួលបានការលើកទឹកចិត្តពន្ធដារ ដូចមានកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា៣ នៃអនុក្រឹត្យនេះ។

ការលើកទឹកចិត្តពន្ធដារមានរយៈពេល ២ (ពីរ) ឆ្នាំ និងត្រូវគិតចាប់ផ្ដើមពី៖

១-ដើមឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ដើមឆ្នាំជាប់ពន្ធនោះ។

២-ដើមឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ចុងឆ្នាំជាប់ពន្ធ។

៣-អំឡុងពេលណាមួយដែលទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤.- លក្ខខណ្ឌដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល**

ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល ត្រូវបានកំណត់អំពីលក្ខខណ្ឌដូចខាងក្រោម៖

១-ក្រុមហ៊ុន/សហគ្រាសដែលបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទំហំលើសពី ២០ (ម្ភៃ) ភាគរយ នៃសិទ្ធិបោះឆ្នោត និង/ឬ បោះផ្សាយមូលបត្របំណុលក្នុងទំហំលើសពី ២០ (ម្ភៃ) ភាគរយ នៃទ្រព្យសកម្មសរុប និងមានឥណប្រតិទានយ៉ាងតិច ៧ (ប្រាំពីរ) ឆ្នាំ នឹងទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូលចំនួន ៥០ (ហាសិប) ភាគរយ នៃពន្ធលើប្រាក់ចំណូលត្រូវបង់។

២-ក្រុមហ៊ុន /សហគ្រាសដែលបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទំហំ ២០ (ម្ភៃ) ភាគរយ ឬតិចជាង នៃសិទ្ធិបោះឆ្នោត និង/ឬ បោះផ្សាយមូលបត្របំណុលក្នុងទំហំ ២០ (ម្ភៃ) ភាគរយ ឬ តិចជាងនៃទ្រព្យសកម្មសរុបនឹងទទួលបាននូវការលើកទឹកចិត្តពន្ធតាមសមាមាត្រចុះដោយយក ២០,០០១ ជាគោល (ដូចមានក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ) ដែលក្នុងនោះ៖

-ការបោះផ្សាយមូលបត្រកម្មសិទ្ធិ៖ ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលតាមសមាមាត្រ មិនឱ្យលើសពី ២០ (ម្ភៃ) ប៊ីលានរៀល។

-ការបោះផ្សាយមូលបត្របំណុល៖ ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលតាមសមាមាត្រ មិនឱ្យលើសពី ៨ (ប្រាំបី) ប៊ីលានរៀល។

ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលជាសាធារណៈ ដើម្បីទទួលបានហិរញ្ញប្បទានក្នុងគោលដៅនៃការអភិវឌ្ឍបៃតង និងប្រកបដោយចីរភាព ឬការអភិវឌ្ឍក្នុងវិស័យអាទិភាពណាមួយ នឹងទទួលបានការលើកទឹកចិត្តពន្ធដារពិសេសបន្ថែម តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥.-** ការអនុគ្រោះបំណុលពន្ធចំពោះក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ

ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវទទួលបានការអនុគ្រោះបំណុលពន្ធដែលរួមបញ្ចូលពន្ធលើប្រាក់ចំណូលទាំងស្រុង ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ។ ការអនុគ្រោះបំណុលពន្ធទាំងស្រុងត្រូវអនុវត្តដូចខាងក្រោម៖

១-បំណុលពន្ធចាប់ពីកាលបរិច្ឆេទ N-3 ដល់ N-10 សម្រាប់ក្រុមហ៊ុន/សហគ្រាសដែលបានបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីនៅទីផ្សារគោល។

២-បំណុលពន្ធចាប់ពីកាលបរិច្ឆេទ N-2 ដល់ N-10 សម្រាប់សហគ្រាសធុនតូច និងមធ្យមដែលបានបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីនៅទីផ្សារកំណើន។ (ឆ្នាំ N គឺជាឆ្នាំដែលក្រុមហ៊ុន/សហគ្រាសធ្វើការបោះ-ផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលជាសាធារណៈជាលើកដំបូង។)

ការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត មិនតម្រូវឱ្យមានការធ្វើសវនកម្មពេញលេញជាមុនពីអគ្គនាយកដ្ឋានពន្ធដារនោះទេ។ សម្រាប់ការស្នើសុំបោះផ្សាយ ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ត្រូវផ្តល់ជូន **ន.ម.ក.** នូវវិញ្ញាបនបត្របញ្ជាក់កាតព្វកិច្ចពន្ធចេញដោយអគ្គនាយកដ្ឋានពន្ធដារ ដែលជាលិខិតសម្រាប់បញ្ជាក់ពីការប្រកាស និងបង់ពន្ធជាប្រចាំដោយមិនទាន់រងការធ្វើសវនកម្មពីអគ្គនាយកដ្ឋានពន្ធដារ។

**មាត្រា៦.-** ការលើកទឹកចិត្តពន្ធកាត់ទុក **និងពន្ធលើចំណេញមូលធនដល់អ្នកវិនិយោគមូលបត្រ**

អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយ លើការប្រាក់ និង/ឬ ភាគលាភដែលបានមកពីការកាន់កាប់ និង/ឬ ការទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល និងត្រូវបានលើកលែងពន្ធលើចំណេញមូលធន ចំពោះការទិញ និងការជួញដូរមូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលសម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

បុគ្គលជាភ្នាក់ងារកាត់ទុកដែលធ្វើការបើកការប្រាក់ និង/ឬ ភាគលាភ ត្រូវធ្វើការគណនាប្រាក់ពន្ធកាត់ទុកដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ មុនការបើកប្រាក់ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ (ម្ភៃ) នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក។

ការកំណត់អត្រាពន្ធលើការប្រាក់នៃមូលបត្ររដ្ឋ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញ-វត្ថុ។

**មាត្រា៧.-** ក្រុមហ៊ុន/សហគ្រាសដែលមិនត្រូវបានទទួលការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល

ក្រុមហ៊ុន/សហគ្រាសមិនត្រូវទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងមាត្រា៣ និងមាត្រា៥ នៃអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុននោះជាសហគ្រាសវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលកំពុងស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ដូចមានចែងក្នុងច្បាប់និងបទ-ប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៨.-** ការបញ្ឈប់ និងការដកហូតការលើកទឹកចិត្តពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារអាចស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈ **ន.ម.ក.** ដើម្បីបញ្ឈប់ និងដកហូតការលើកទឹកចិត្តពន្ធដារដូចមានចែងក្នុងមាត្រា៣ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុង មាត្រា៥ នៃអនុក្រឹត្យនេះ ក្នុងករណីក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្រ បំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រ នៅទីផ្សារមូលបត្រប្រតិស្រុតៈ

-មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ និងបង់ប្រាក់ពន្ធ តាមកាលកំណត់របស់រដ្ឋបាល សារពើពន្ធ។

-មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធ និងបង់ប្រាក់ពន្ធតាមកាល កំណត់របស់រដ្ឋបាលសារពើពន្ធ។ លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មនៅក្នុងវិស័យមូលបត្រ រួមមាន តារាង តុល្យការ គណនីលទ្ធផល តារាងចលនាសាច់ប្រាក់ និងកំណត់សម្គាល់ដោយមិនឱ្យហួសពីរយៈពេល ៣ (បី) ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ។

-មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើសវនកម្មលើបញ្ជិកាគណនេយ្យ ឬឯកសារផ្សេងៗ។

-មិនបានបង់ពន្ធអាករទាំងអស់ ពន្ធបន្ថែម និងការប្រាក់ ដែលបានកំណត់សម្រាប់រយៈពេលជាប់ ពន្ធដែលបានធ្វើសវនកម្មរួចដោយរដ្ឋបាលសារពើពន្ធ។

-អគ្គនាយកដ្ឋានពន្ធដាររកឃើញថាក្រុមហ៊ុន/សហគ្រាសមានចេតនាគេចវេះពន្ធ តាមរយៈការ បោះផ្សាយមូលបត្រលើកដំបូងជាសាធារណៈ។

ក្នុងករណីក្រុមហ៊ុន/សហគ្រាសដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែង ក្នុងអនុក្រឹត្យនេះ មិនបានអនុវត្តតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទ-ប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យមូលបត្រ **ន.ម.ក.** អាចស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបញ្ឈប់ ការលើកទឹកចិត្តដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៣ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុង មាត្រា៥ នៃអនុក្រឹត្យនេះ។

ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុតមិនត្រូវ ទទួលបាននូវការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុន/ សហគ្រាសនោះបានដកខ្លួនចេញពីការចុះបញ្ជី ឬត្រូវបានដកពីការចុះបញ្ជីជួញដូរមូលបត្រនៅក្នុងទីផ្សារ មូលបត្រប្រតិស្រុត។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៩.-** ការលើកទឹកចិត្តពន្ធដារចំពោះក្រុមហ៊ុន/សហគ្រាសដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈរួច

ក្រុមហ៊ុន/សហគ្រាសដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** ធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងដែលបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រ ប្រតិស្រុតរួចហើយ តែមិនទាន់ទទួលបាននូវការលើកទឹកចិត្តពន្ធដារនោះ ត្រូវបានផ្តល់ការលើកទឹកចិត្តពន្ធដារ ដូចមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ។

**មាត្រា១០.-** ការជំនួស

អនុក្រឹត្យនេះត្រូវមានសុពលភាពអនុវត្តបន្តពីអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ។ បញ្ញត្តិទាំងឡាយដែលចេញឡើងស្របតាម អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ នឹងត្រូវបន្តអនុវត្តអនុលោមតាមអនុក្រឹត្យនេះ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១.-** ការអនុវត្ត

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ

### នៃអនុក្រឹតលេខ .៣៩... អនក្រ.បក ចុះថ្ងៃទី .១៤. ខែមីនា ឆ្នាំ...២០២៥......
### ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

* * * *

## តារាងសមាមាត្រក្នុងការផ្តល់ការលើកទឹកចិត្តពន្ធដារ
## ដោយយកទំហំនៃការបោះផ្សាយ ២០,០០១* ជាគោល

| ល.រ | ទំហំបោះផ្សាយ | សមាមាត្រភាគរយនៃការលើកទឹកចិត្តទទួលបាន | ភាគរយនៃការលើកទឹកចិត្តលើប្រាក់ពន្ធត្រូវបង់ប្រចាំឆ្នាំ (ដូចក្នុងអនុក្រឹត្យ) |
|---|---|---|---|
| | A | B = A / 20.001% | C = B * 50% |
| 1 | ចាប់ពី 20.001% | 100.000% | 50.000% |
| 2 | 20.000% | 99.995% | 49.9975% |
| 3 | 19.500% | 97.495% | 48.748% |
| 4 | 19.000% | 94.995% | 47.498% |
| 5 | 18.500% | 92.495% | 46.248% |
| 6 | 18.000% | 89.996% | 44.998% |
| 7 | 17.500% | 87.496% | 43.748% |
| 8 | 17.000% | 84.996% | 42.498% |
| 9 | 16.500% | 82.496% | 41.248% |
| 10 | 16.000% | 79.996% | 39.998% |
| 11 | 15.500% | 77.496% | 38.748% |
| 12 | 15.000% | 74.996% | 37.498% |
| 13 | 14.500% | 72.496% | 36.248% |
| 14 | 14.000% | 69.997% | 34.998% |
| 15 | 13.500% | 67.497% | 33.748% |
| 16 | 13.000% | 64.997% | 32.498% |
| 17 | 12.500% | 62.497% | 31.248% |
| 18 | 12.000% | 59.997% | 29.999% |
| 19 | 11.500% | 57.497% | 28.749% |
| 20 | 11.000% | 54.997% | 27.499% |
| 21 | 10.500% | 52.497% | 26.249% |
| 22 | 10.000% | 49.998% | 24.999% |
| 23 | 9.500% | 47.498% | 23.749% |
| 24 | 9.000% | 44.998% | 22.499% |

| | | | |
|---|---|---|---|
| 25 | 8.500% | 42.498% | 21.249% |
| 26 | 8.000% | 39.998% | 19.999% |
| 27 | 7.500% | 37.498% | 18.749% |
| 28 | 7.000% | 34.998% | 17.499% |
| 29 | 6.500% | 32.498% | 16.249% |
| 30 | 6.000% | 29.999% | 14.999% |
| 31 | 5.500% | 27.499% | 13.749% |
| 32 | 5.000% | 24.999% | 12.499% |
| 33 | 4.500% | 22.499% | 11.249% |
| 34 | 4.000% | 19.999% | 10.000% |
| 35 | 3.500% | 17.499% | 8.750% |
| 36 | 3.000% | 14.999% | 7.500% |
| 37 | 2.500% | 12.499% | 6.250% |
| 38 | 2.000% | 10.000% | 5.000% |
| 39 | 1.500% | 7.500% | 3.750% |
| 40 | 1.000% | 5.000% | 2.500% |

សម្គាល់៖

$$\text{ភាគរយនៃការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល} = \frac{\text{ទំហំបោះផ្សាយធៀបនឹងសិទ្ធិបោះឆ្នោតសរុប ឬទ្រព្យសកម្មសរុប}}{\text{ទំហំបោះផ្សាយគោល (20.001\%)}} \times 50\%$$

*សម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិ៖ ទំហំបោះផ្សាយត្រូវធៀបនឹងចំនួនមូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតសរុប។

*សម្រាប់ការបោះផ្សាយមូលបត្របំណុល៖ ទំហំបោះផ្សាយត្រូវធៀបនឹងទ្រព្យសកម្មសរុប។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# មូលនិធិកីឡាយុវជនអាស៊ីហ្គេមកម្ពុជាឆ្នាំ២០២៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១ .-**

ត្រូវបានបង្កើត **មូលនិធិកីឡាយុវជនអាស៊ីហ្គេមកម្ពុជាឆ្នាំ២០២៩** សរសេរជាអក្សរកាត់ថា "**ម.ក.យ.អ.ក-២០២៩**" និងមានឈ្មោះជាអក្សរឡាតាំង CAMBODIA ASIAN YOUTH GAME FUND 2029 (CAYGF-2029) ដើម្បីគ្រប់គ្រងថវិកាវិភាគទានរបស់រាជរដ្ឋាភិបាល សម្រាប់ការរៀបចំព្រឹត្តិការណ៍កីឡាយុវជនអាស៊ីហ្គេមកម្ពុជាឆ្នាំ២០២៩។

**មាត្រា២ .-**

កញ្ចប់ថវិកាវិភាគទានប្រចាំឆ្នាំរបស់ **ម.ក.យ.អ.ក-២០២៩** ត្រូវបានគ្រោងក្នុងកញ្ចប់ថវិកាចំណាយមិនបានគ្រោងទុករបស់រាជរដ្ឋាភិបាល និងត្រូវផ្ទេរចូលគណនីរបស់ **ម.ក.យ.អ.ក-២០២៩** តាមរយៈក្រសួងអប់រំ យុវជន និងកីឡា ដើម្បីកត់ត្រាចំណាយថវិកាវិភាគទានប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល។

**មាត្រា៣ .-**

**ម.ក.យ.អ.ក-២០២៩** ត្រូវបានអនុញ្ញាតឱ្យរក្សាទុកក្នុងគណនីប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា ដែលមានឈ្មោះថា **គណនីមូលនិធិកីឡាយុវជនអាស៊ីហ្គេមកម្ពុជាឆ្នាំ២០២៩**។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាម្ចាស់នៃគណនីមូលនិធិកីឡាយុវជនអាស៊ីហ្គេមកម្ពុជាឆ្នាំ២០២៩ នេះ។

**មាត្រា៤ .-**

ការបើកផ្តល់ថវិកា **ម.ក.យ.អ.ក-២០២៩** សម្រាប់ការរៀបចំកីឡាយុវជនអាស៊ីហ្គេមកម្ពុជាឆ្នាំ២០២៩ ត្រូវធ្វើឡើងតាមការពិនិត្យ និងសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញប្រកាសស្តីពីនីតិវិធីអនុវត្តថវិកាលម្អិតបន្ថែមតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិកា **ម.ក.យ.អ.ក-២០២៩**។

**មាត្រា៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



6

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤១ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៤/០០៨ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៩១ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូក និងតាមកម្មវិធីនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យធ្វើការផ្ទេរឥណទានថវិកាចំនួន ២៦ ៨៧៨ ០០០ ០០០រៀល (ម្ភៃប្រាំមួយបីលានប្រាំបីរយចិតសិបប្រាំបីលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) មកជំពូក ៦០ (ការទិញ) ជូនរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥។

**មាត្រា២ .–**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ចំណាយទិញឧបករណ៍បច្ចេកទេស សម្ភារៈ និងគ្រឿងបន្លាស់ឧបករណ៍ឧតុនិយម ដើម្បីបំពាក់នៅអាកាសយានដ្ឋានអន្តរជាតិតេជោ ដំណាក់កាលទី២ (បញ្ចប់) ឆ្នាំ២០២៥។

**មាត្រា៣ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៥រោច ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៤/០០៨ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៩១ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូក និងតាមកម្មវិធីនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យធ្វើការផ្ទេរឥណទានថវិកាចំនួន ៤ ០០០ ០០០ ០០០រៀល (បួនប៊ីលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) មកជំពូក ៦១ (សេវាកម្ម) ជូនក្រសួងបរិស្ថាន សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥។

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការជួសជុលដំបូលទីស្តីការក្រសួងបរិស្ថាន ដែលមានសភាពចាស់ និងមានស្នាមប្រេះតាមជញ្ជាំង។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៥រោច ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តទណ្ឌកម្មខាងវិន័យចំពោះមន្ត្រីនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.-**

ត្រូវបានដាក់ឱ្យចូលនិវត្តន៍មុនកំណត់ចំពោះ វរសេនីយ៍ឯក ស៊ីង ចាន់អូន អត្តលេខ ២៤៧០៥ នាយនគរបាលជាន់ខ្ពស់ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ ៗផ ៦ រោច ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២៣៨ អនក្រ.បក

**អនុក្រឹត្យ**
**ស្ដីពីការផ្ដល់មេដាយការងារ**
**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ៨០រូប នៃរដ្ឋបាលខេត្តកំពង់ស្ពឺ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

| | | | |
|---|---|---|---|
| ១- | លោក | យន ម៉ាលីវ៉ាន់ | ប្រធានការិយាល័យ រដ្ឋបាលខេត្តកំពង់ស្ពឺ |
| ២- | លោក | ប៊ិន ថាវរៈ | អភិបាលរងនៃគណៈអភិបាលក្រុងច្បារមន |
| ៣- | លោក | បែន សុខុម | អភិបាលរងនៃគណៈអភិបាលក្រុងច្បារមន |

| | | | |
|---|---|---|---|
| ៤- | លោកស្រី | សាយ រស្មី | ប្រធានការិយាល័យ រដ្ឋបាលក្រុងច្បារមន |
| ៥- | លោក | ហេង សំណាង | អនុប្រធានការិយាល័យ រដ្ឋបាលក្រុងច្បារមន |
| ៦- | លោក | សុខ ចន្ថា | ស្មៀនសង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន |
| ៧- | លោកស្រី | មុយ សុខឡាយ | ស្មៀនសង្កាត់ច្បារមន ក្រុងច្បារមន |
| ៨- | លោក | ឡាក់ ប៊ុនធីម | មន្ត្រី នៃរដ្ឋបាលក្រុងច្បារមន |
| ៩- | លោក | ណៃ សូនី | អភិបាលរងនៃគណៈអភិបាលស្រុកបសេដ្ឋ |
| ១០- | លោក | កែវ សំអឿន | នាយករដ្ឋបាលស្រុកបសេដ្ឋ |
| ១១- | លោក | សុខ ចំរើន | នាយករងរដ្ឋបាលស្រុកសំរោងទង |
| ១២- | លោកស្រី | អ៊ុំ ស្រីនិច | ប្រធានការិយាល័យ រដ្ឋបាលស្រុកសំរោងទង |
| ១៣- | លោក | យិន ប៊ុនធឿន | អនុប្រធានការិយាល័យ រដ្ឋបាលស្រុកសំរោងទង |
| ១៤- | លោក | សម្បត្តិ វឌ្ឍនៈ | អភិបាលរងនៃគណៈអភិបាលស្រុកឱរ៉ាល់ |
| ១៥- | លោក | សួស ប៊ុនធឿន | អភិបាលរងនៃគណៈអភិបាលស្រុកឱរ៉ាល់ |
| ១៦- | លោក | រចម សារ៉ែន | អភិបាលរងនៃគណៈអភិបាលស្រុកឱរ៉ាល់ |
| ១៧- | លោក | ទេព សម្បត្តិ | អនុប្រធានផ្នែក នៃរដ្ឋបាលខេត្តកំពង់ស្ពឺ |
| ១៨- | លោក | ហែម បូរាណ | អភិបាលរងនៃគណៈអភិបាលក្រុងឧដុង្គម៉ែជ័យ |
| ១៩- | លោក | លី រិទ្ធី | មន្ត្រី នៃរដ្ឋបាលក្រុងឧដុង្គម៉ែជ័យ |
| ២០- | លោក | ឡុង សំអុល | អនុប្រធានការិយាល័យ រដ្ឋបាលខេត្តកំពង់ស្ពឺ |
| ២១- | លោកស្រី | ទូច ថាវី | អនុប្រធានការិយាល័យ រដ្ឋបាលខេត្តកំពង់ស្ពឺ |
| ២២- | លោកស្រី | ស៊ីវ សុខុម | មន្ត្រី នៃរដ្ឋបាលខេត្តកំពង់ស្ពឺ |
| ២៣- | លោកស្រី | គ្រោក សុផារី | មន្ត្រី នៃរដ្ឋបាលខេត្តកំពង់ស្ពឺ |
| ២៤- | លោកស្រី | កែវ កក្កដា | មន្ត្រី នៃរដ្ឋបាលខេត្តកំពង់ស្ពឺ |
| ២៥- | លោក | កែវ មូល | ប្រធានការិយាល័យ រដ្ឋបាលស្រុកភ្នំស្រួច |
| ២៦- | លោក | ស្វាយ សុភាក់ | អនុប្រធានការិយាល័យ រដ្ឋបាលស្រុកភ្នំស្រួច |
| ២៧- | លោក | អ៊ួង សុភ័ណ្ឌ | ស្មៀនឃុំអូរ ស្រុកភ្នំស្រួច |
| ២៨- | លោក | គៀត សុខន | ស្មៀនឃុំព្រៃរំដួល ស្រុកភ្នំស្រួច។ |

ខ-មេដាយ **ប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១- | លោក | ភ័ណ្ឌ សុវណ្ណារិទ្ធិ | អនុប្រធានការិយាល័យ រដ្ឋបាលខេត្តកំពង់ស្ពឺ |
| ២- | លោក | កង សុចិត្រ | មន្ត្រី នៃរដ្ឋបាលខេត្តកំពង់ស្ពឺ |
| ៣- | លោក | ខឹម សុវណ្ណារិទ្ធ | មន្ត្រី នៃរដ្ឋបាលខេត្តកំពង់ស្ពឺ |
| ៤- | លោក | ឈឹម សន | អនុប្រធានការិយាល័យ រដ្ឋបាលខេត្តកំពង់ស្ពឺ |
| ៥- | លោកស្រី | វ៉ាន់ វត្តី | មន្ត្រី នៃរដ្ឋបាលខេត្តកំពង់ស្ពឺ |
| ៦- | លោក | អ៊ុង រដ្ឋា | អភិបាលរងនៃគណៈអភិបាលក្រុងច្បារមន |
| ៧- | លោក | យន់ សេងហួត | ប្រធានការិយាល័យ រដ្ឋបាលក្រុងច្បារមន |
| ៨- | លោក | វ៉ាន់ ស៊ីធឿន | ប្រធានការិយាល័យ រដ្ឋបាលក្រុងច្បារមន |

| | | | |
|---|---|---|---|
| ៩- | លោក | ហឿន ពន្លក | អនុប្រធានការិយាល័យ រដ្ឋបាលក្រុងច្បារមន |
| ១០- | លោកស្រី | ទូច កក្កដា | អនុប្រធានការិយាល័យ រដ្ឋបាលក្រុងច្បារមន |
| ១១- | លោក | វើន សុជា | អនុប្រធានការិយាល័យ រដ្ឋបាលក្រុងច្បារមន |
| ១២- | លោក | សឿ សុខា | អនុប្រធានការិយាល័យ រដ្ឋបាលក្រុងច្បារមន |
| ១៣- | លោកស្រី | គ្រួច សោភ័ណ្ឌ | អនុប្រធានការិយាល័យ រដ្ឋបាលក្រុងច្បារមន |
| ១៤- | លោក | ផន វាសនា | នាយករងរដ្ឋបាលស្រុកបសេដ្ឋ |
| ១៥- | លោកស្រី | សម ស្រីមុំ | អនុប្រធានការិយាល័យ រដ្ឋបាលស្រុកបសេដ្ឋ |
| ១៦- | លោក | អ៊ិន សារ៉ុន | ប្រធានការិយាល័យ រដ្ឋបាលស្រុកសំរោងទង |
| ១៧- | លោក | ជា សុវណ្ណ | ប្រធានការិយាល័យ រដ្ឋបាលស្រុកសំរោងទង |
| ១៨- | លោក | សួស សុខា | នាយករដ្ឋបាលស្រុកភ្នំស្រួច |
| ១៩- | លោកស្រី | ហ៊ុន ឃុនណៃ | នាយករងរដ្ឋបាលស្រុកភ្នំស្រួច |
| ២០- | លោកស្រី | ប៊ុន ស្រីទូច | ប្រធានការិយាល័យ រដ្ឋបាលស្រុកភ្នំស្រួច |
| ២១- | លោក | ឡួត សៀក | ប្រធានការិយាល័យ រដ្ឋបាលស្រុកភ្នំស្រួច |
| ២២- | លោក | ធឹង គឹមថាន | ប្រធានការិយាល័យ រដ្ឋបាលស្រុកភ្នំស្រួច |
| ២៣- | លោក | តិច សេងឡុង | អនុប្រធានការិយាល័យ រដ្ឋបាលស្រុកភ្នំស្រួច |
| ២៤- | លោក | ចាន់ វិរៈ | អនុប្រធានការិយាល័យ រដ្ឋបាលស្រុកភ្នំស្រួច |
| ២៥- | លោក | សាន ប្រុស | អនុប្រធានការិយាល័យ រដ្ឋបាលស្រុកភ្នំស្រួច |
| ២៦- | លោកស្រី | សុខ លក្ខិណា | ស្មៀនឃុំព្រៃក្មេង ស្រុកភ្នំស្រួច |
| ២៧- | លោកស្រី | ជិន សំអាត | ស្មៀនឃុំតាំងស្យា ស្រុកភ្នំស្រួច |
| ២៨- | លោក | ស៊ួន និមល | ស្មៀនឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច |
| ២៩- | លោក | យឹម យ៉ាណា | ប្រធានការិយាល័យ រដ្ឋបាលក្រុងឧដុង្គម៉ែជ័យ |
| ៣០- | លោកស្រី | សួន ពិសី | អនុប្រធានការិយាល័យ រដ្ឋបាលខេត្តកំពង់ស្ពឺ |
| ៣១- | លោក | យ៉ន ចាន់បូ | មន្ត្រី នៃរដ្ឋបាលខេត្តកំពង់ស្ពឺ |
| ៣២- | លោកស្រី | ទូច ស្រីនាថ | មន្ត្រី នៃរដ្ឋបាលខេត្តកំពង់ស្ពឺ។ |

គ-មេដាយ **សំរឹទ្ធភាពរសារ**

| | | | |
|---|---|---|---|
| ១- | លោក | ដួង វិបុលរាជសុវណ្ណសិលា | អភិបាលរងនៃគណៈអភិបាលស្រុកសំរោងទង |
| ២- | លោក | ម៉ាន់ ទើង | អនុប្រធានការិយាល័យ រដ្ឋបាលស្រុកសំរោងទង |
| ៣- | លោក | ហ៊ុយ សារឹម | អនុប្រធានការិយាល័យ រដ្ឋបាលស្រុកសំរោងទង |
| ៤- | លោក | អ៊ូច សារុំ | អនុប្រធានការិយាល័យ រដ្ឋបាលស្រុកសំរោងទង |
| ៥- | លោកស្រី | ណៃត ស្រីទន់ | មន្ត្រី នៃរដ្ឋបាលស្រុកសំរោងទង |
| ៦- | លោក | វង្ស ចាន់តារាថារិទ្ធ | មន្ត្រី នៃរដ្ឋបាលស្រុកសំរោងទង |
| ៧- | លោក | អ៊ូច សៀកហុង | មន្ត្រី នៃរដ្ឋបាលស្រុកសំរោងទង |
| ៨- | លោក | គង់ សុខន | ស្មៀនឃុំវល្លិសរ ស្រុកសំរោងទង |
| ៩- | លោក | សាយ ទិត្យពិសី | អភិបាលរងនៃគណៈអភិបាលស្រុកភ្នំស្រួច |

| | | | |
|---|---|---|---|
| ១០- | លោកស្រី | នួន ស៊ី | អនុប្រធានការិយាល័យ រដ្ឋបាលស្រុកភ្នំស្រួច |
| ១១- | លោក | មឿង សាម៉េត | ស្មៀនឃុំជាំសង្កែ ស្រុកភ្នំស្រួច |
| ១២- | លោក | មុំ សំណាង | មន្ត្រី នៃរដ្ឋបាលខេត្តកំពង់ស្ពឺ |
| ១៣- | លោក | ព្រាប កុយវឌ្ឍនៈ | អភិបាលនៃគណៈអភិបាលក្រុងឧដុង្គម៉ែជ័យ |
| ១៤- | លោក | គង់ សុផាន់ណ្ណៈ | អភិបាលរងនៃគណៈអភិបាលក្រុងឧដុង្គម៉ែជ័យ |
| ១៥- | លោក | ហ៊ិន សុខឡេង | មន្ត្រី នៃរដ្ឋបាលក្រុងឧដុង្គម៉ែជ័យ |
| ១៦- | លោក | សុខ កែវពន្លឺ | មន្ត្រី នៃរដ្ឋបាលក្រុងឧដុង្គម៉ែជ័យ |
| ១៧- | លោក | ពិន រៀម | មន្ត្រី នៃរដ្ឋបាលខេត្តកំពង់ស្ពឺ |
| ១៨- | លោក | សល់ សុវ៉ាន់ឌី | មន្ត្រី នៃរដ្ឋបាលខេត្តកំពង់ស្ពឺ |
| ១៩- | លោក | ធន វិបុល | មន្ត្រី នៃរដ្ឋបាលខេត្តកំពង់ស្ពឺ |
| ២០- | លោក | រឿន ធីតា | អភិបាលរងនៃគណៈអភិបាលក្រុងច្បារមន។ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦ រោច ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ មីនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៣៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃរដ្ឋបាលខេត្តកណ្តាល ចំនួន ២៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

| | |
|---|---|
| ១-លោក អុល ចាន់ណូ | អភិបាលរងនៃគណៈអភិបាលក្រុងសំពៅពូន |
| ២-លោក គឹម សម្បត្តិ | នាយកទីចាត់ការ រដ្ឋបាលខេត្តកណ្តាល |

| | |
|---|---|
| ៣-លោក ញ៉ែម សារ៉ែន | ប្រធានការិយាល័យ រដ្ឋបាលក្រុងអរិយក្សត្រ |
| ៤-លោក ហៃ គឹមសួរ | ប្រធានការិយាល័យ រដ្ឋបាលខេត្តកណ្តាល |
| ៥-លោក យក់ សំអឿន | អនុប្រធានការិយាល័យ រដ្ឋបាលខេត្តកណ្តាល។ |

ខ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

| | |
|---|---|
| ១-លោក ឡាយ សំរិទ្ធ | អភិបាលរងនៃគណៈអភិបាលក្រុងតាខ្មៅ |
| ២-លោក ជា គឹមឡេង | អភិបាលរងនៃគណៈអភិបាលស្រុកខ្សាច់កណ្តាល |
| ៣-លោក វ៉ាត វ៉ៃ | អនុប្រធានការិយាល័យ រដ្ឋបាលខេត្តកណ្តាល |
| ៤-លោកស្រី ឡាយ ដាលីន | នាយករងទីចាត់ការ រដ្ឋបាលខេត្តកណ្តាល |
| ៥-លោកស្រី ព្រំ សុខេង | ប្រធានការិយាល័យ រដ្ឋបាលស្រុកមុខកំពូល |
| ៦-លោក ប៊ុន ហុង | មន្ត្រី នៃរដ្ឋបាលស្រុកមុខកំពូល។ |

គ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ**

| | |
|---|---|
| ១-លោកស្រី ណម រតនា | នាយករងទីចាត់ការ រដ្ឋបាលខេត្តកណ្តាល |
| ២-លោក ឈុន វីរៈ | មន្ត្រី នៃរដ្ឋបាលខេត្តកណ្តាល |
| ៣-លោកស្រី ចាប ចាន់ណារី | មន្ត្រី នៃរដ្ឋបាលខេត្តកណ្តាល |
| ៤-លោក នី សំនៀង | ស្មៀនឃុំពើក ស្រុកអង្គស្នួល |
| ៥-លោក យុត ផល្លា | អភិបាលរងនៃគណៈអភិបាលស្រុកស្អាង |
| ៦-លោកស្រី សែម ចាន់ថូ | អភិបាលរងនៃគណៈអភិបាលស្រុកស្អាង |
| ៧-លោក ជឿន វិចិត្រ | នាយករដ្ឋបាលក្រុងតាខ្មៅ |
| ៨-លោក ម៉ូ សំអុល | មន្ត្រី នៃរដ្ឋបាលក្រុងតាខ្មៅ |
| ៩-លោក គង់ គឹមជឿន | ស្មៀនសង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ |
| ១០-លោក សំអាត សុខជាតិ | ស្មៀនសង្កាត់ព្រែកហូរ ក្រុងតាខ្មៅ |
| ១១-លោក សាយ ដា | នាយករងរដ្ឋបាលស្រុកខ្សាច់កណ្តាល |
| ១២-លោក ណាយ ឆេងនីម | ស្មៀនឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល |
| ១៣-លោក អោម សំអុល | ស្មៀនឃុំស៊ីធរ ស្រុកខ្សាច់កណ្តាល |
| ១៤-លោកស្រី ឈឿន សុកល | ស្មៀនសង្កាត់ព្រែកលួង ក្រុងអរិយក្សត្រ |

១៥-លោក រឹម រក្សា ស្មៀនសង្កាត់កោះឧកញ៉ាតី ក្រុងអរិយក្សត្រ។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦ រោច ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៤០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃរដ្ឋបាលខេត្តកណ្តាល ចំនួន ៨៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

| | |
|---|---|
| ១-លោកស្រី ស៊្រុន ស្រីនាង | អភិបាលរងនៃគណៈអភិបាលខេត្តកណ្តាល |
| ២-លោក រឿង វីរៈ | នាយករងរដ្ឋបាលស្រុកលើកដែក |
| ៣-លោក ចេង ចាន់ទិត្យា | នាយករដ្ឋបាលស្រុកមុខកំពូល |
| ៤-លោក សេង សុផល | ប្រធានការិយាល័យ រដ្ឋបាលស្រុកមុខកំពូល |

| | |
|---|---|
| ៥-លោក តេក សុថា | ប្រធានការិយាល័យ រដ្ឋបាលស្រុកមុខកំពូល |
| ៦-លោក លន គន្ធី | អនុប្រធានការិយាល័យ រដ្ឋបាលខេត្តកណ្ដាល |
| ៧-លោក ទេព ភារុណ | ប្រធានការិយាល័យ រដ្ឋបាលខេត្តកណ្ដាល |
| ៨-លោក ហៃ សុងទ្រី | អនុប្រធានការិយាល័យ រដ្ឋបាលខេត្តកណ្ដាល |
| ៩-លោក ហែន តុលា | អនុប្រធានការិយាល័យ រដ្ឋបាលស្រុកល្វាឯម។ |

ខ-មេដាយ **ប្រាក់ការងារ**

| | |
|---|---|
| ១-លោក គឹម ឥស្សរ៉ូ | អនុប្រធានការិយាល័យ រដ្ឋបាលខេត្តកណ្ដាល |
**គ.ខ.ឡាំសាន** មានសិទ្ធិអញ្ជើញ ស្ថាប័នស្រាវជ្រាវ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងជំនាញការ ដើម្បីផ្តល់ព័ត៌មាន និងយោបល់នានា សម្រាប់គោលបំណងសិក្សាស្រាវជ្រាវ និងរៀបចំគម្រោង ដែលស្ថិតក្រោមវិសាលភាពនៃកម្មវិធីពិសេស។

**គ.ខ.ឡាំសាន** មានសិទ្ធិជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីរៀបចំ ត្រួតពិនិត្យ និងវាយតម្លៃគម្រោងដែលស្ថិតក្រោមវិសាលភាពនៃកម្មវិធីពិសេស និងបំពេញភារកិច្ចដទៃទៀត តាមការណែនាំរបស់ប្រធាន **គ.ខ.ឡាំសាន**។

**ប្រការ៧.-**

**គ.ខ.ឡាំសាន** មានលេខាធិការដ្ឋានមួយជាសេនាធិការ។ លេខាធិការដ្ឋាន **គ.ខ.ឡាំសាន** មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ស៊ឹម វីរៈ** | អនុរដ្ឋលេខាធិការ ក.ស.ហ.វ. និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | ប្រធាន |
| ២. ឯកឧត្តម **ពេជ្រ សម្បត្តិ** | អនុរដ្ឋលេខាធិការ ក.ស.ហ.វ. | អនុប្រធាន |
| ៣. លោក **សុ សោភ័ណវិចិត្រ** | អនុប្រធាននាយកដ្ឋានប្រសិទ្ធភាពចំណាយ ក.ស.ហ.វ. និងជាជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | អនុប្រធាន |
| ៤. លោក **ម៊ុន ជីវ** | ប្រធាននាយកដ្ឋានរបបគយ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក.ស.ហ.វ. | សមាជិក |
| ៥. លោក **ម៉ែន គុន** | នាយករងរដ្ឋបាល នៃរដ្ឋបាលខេត្តស្ទឹងត្រែង | សមាជិក |
| ៦. លោក **កុយ រតនា** | នាយកទីចាត់ការផែនការ និងវិនិយោគ នៃរដ្ឋបាលខេត្តមណ្ឌលគិរី | សមាជិក |
| ៧. លោក **ឡេង តា** | នាយកទីចាត់ការផែនការ និងវិនិយោគ នៃរដ្ឋបាលខេត្តរតនគិរី | សមាជិក |
| ៨. លោក **សាមុត លីម៉ា** | នាយកទីចាត់ការផែនការ និងវិនិយោគ នៃរដ្ឋបាលខេត្តក្រចេះ | សមាជិក |
| ៩. លោក **ផេង អ៊ី** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន ក.ស.ហ.វ. | សមាជិក |
| ១០. លោក **ខាំ គុន** | ប្រធានការិយាល័យវិនិយោគ នៃរដ្ឋបាលខេត្តរតនគិរី | សមាជិក |
| ១១. លោក **ប្រាជ្ញ ឡឿន** | អនុប្រធានការិយាល័យសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ នៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន ក.ស.ហ.វ. | សមាជិក |

| | | |
|---|---|---|
| ១២. លោក **ស៊ូ ទាសនា** | អនុប្រធានការិយាល័យសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ នៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន ក.ស.ហ.វ. | សមាជិក |
| ១៣. លោក **ស្រី លីហ្សា** | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានគោលនយោបាយ ក.ស.ហ.វ. | សមាជិក |
| ១៤. លោក **មេ ម៉េងអ៊ី** | អនុប្រធានការិយាល័យ នៃនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ ក.ស.ហ.វ. | សមាជិក |
| ១៥. ប្រធានសាខាគយ និងរដ្ឋាករខេត្តក្រចេះ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក.ស.ហ.វ. | | សមាជិក |
| ១៦. ប្រធានសាខាគយ និងរដ្ឋាករខេត្តស្ទឹងត្រែង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក.ស.ហ.វ. | | សមាជិក |
| ១៧. ប្រធានសាខាគយ និងរដ្ឋាករខេត្តរតនគិរី នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក.ស.ហ.វ. | | សមាជិក |
| ១៨. ប្រធានសាខាគយ និងរដ្ឋាករខេត្តមណ្ឌលគិរី នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក.ស.ហ.វ. | | សមាជិក |
| ១៩. លោក **ស៊ាន មនោរិទ្ធ** | មន្ត្រីនៃអគ្គនាយកដ្ឋានគោលនយោបាយ ក.ស.ហ.វ. | សមាជិក |
| ២០. លោក **អ៊ឹម ស៊ុនហេង** | មន្ត្រីនៃអគ្គនាយកដ្ឋានថវិកា ក.ស.ហ.វ. | សមាជិក |
| ២១. លោក **ថង ណារឡុង** | មន្ត្រីនៃអគ្គលេខាធិការដ្ឋាន ក.ស.ហ.វ. | សមាជិក |
| ២២. លោក **យឹម ពិសាល** | មន្ត្រីនៃនាយកដ្ឋានវិភាគគម្រោង និងការលើកទឹកចិត្ត គណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២៣. លោក **សំអាត ច័ន្ទសុមានិត** | ជំនួយការអគ្គលេខាធិការរង គណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២៤. លោក **អ៊ុំ បញ្ញា** | ជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | សមាជិក |
| ២៥. កញ្ញា **ខូច មួយឡេង** | ជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | សមាជិក |
| ២៦. លោក **ខាន់ លីហួរ** | ជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | សមាជិក |
| ២៧. កញ្ញា **គួ សុធារតន៍** | ជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | សមាជិក |
| ២៨. លោក **សុខ សុធារៈ** | ជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | សមាជិក |
| ២៩. លោកស្រី **ឈួ គឹមនាង** | ជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | សមាជិក។ |

**ប្រការ៨.-**

លេខាធិការដ្ឋាន **គ.ទ.ពល្សសាន** ដើរតួនាទីសម្របសម្រួលផ្នែករដ្ឋបាលទាំងអស់ និងមានការិយាល័យនៅរាជធានីភ្នំពេញ និងអាចបង្កើតការិយាល័យតាមបណ្ដាខេត្តនៅភូមិភាគពល្សសាន តាមការចាំបាច់។ លេខាធិការដ្ឋាន **គ.ទ.ពល្សសាន** មានភារកិច្ចដូចខាងក្រោម ៖

- ផ្ដល់សេវាគាំទ្រ និងបំពេញការងារ សម្រាប់ប្រក្រតីភាពនៃកិច្ចដំណើរការប្រចាំថ្ងៃ របស់ **គ.ទ.ពល្សសាន**
- សម្របសម្រួលកិច្ចទំនាក់ទំនងសាធារណៈ ប្រឹក្សាយោបល់ ផ្សព្វផ្សាយ ទាក់ទាញ និងធ្វើបដិសណ្ឋារកិច្ច ដល់វិនិយោគិន ធុរជន និងអ្នកផ្សេងទៀតដែលមានការពាក់ព័ន្ធ

- ពិនិត្យ ប្រមូលធាតុចូល វិភាគ និងវាយតម្លៃលើគម្រោងវិនិយោគដែលបានស្នើសុំ ដើម្បីទទួលបាននូវការលើកទឹកចិត្ត និងការអនុគ្រោះនានាពីរាជរដ្ឋាភិបាល ដែលស្ថិតក្រោមវិសាលភាពនៃកម្មវិធីពិសេស ព្រមទាំងលើកយោបល់ជូន **ក.ទ.ឡស៊ាន** ដើម្បីពិនិត្យ និងសម្រេចអនុម័តគម្រោងវិនិយោគទាំងនោះ
- រៀបចំផែនការសកម្មភាពរបស់លេខាធិការដ្ឋាន **ក.ទ.ឡស៊ាន** ដើម្បីគាំទ្រ និងជំរុញការអនុវត្តកម្មវិធីពិសេសប្រកបដោយប្រសិទ្ធភាព ព្រមទាំងរៀបចំរបាយការណ៍វឌ្ឍនភាពការងារ
- បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់ប្រធាន **ក.ទ.ឡស៊ាន**។

**ប្រការ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៤កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែ មីនា ឆ្នាំ ២០២៥

នាយករដ្ឋមន្ត្រី

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

<u>កន្លែងទទួល ៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច

ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៥ សរ

## សារាចរ

## ស្តីពី

## ការកំណត់ និងការអនុវត្តមុខងារនៅតាមក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ

ផ្អែកលើស្នូលនៃ"**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១**" ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដែលផ្តោតលើអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ រាជរដ្ឋាភិបាលបានកំណត់អភិក្រម "**រៀបចំផ្ទះឱ្យរៀបរយ**" និង "**ពង្រឹងជាជាងពង្រីក**" ដើម្បីធានាការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន ឱ្យមានប្រសិទ្ធភាពខ្ពស់។

កន្លងមក រាជរដ្ឋាភិបាលបានដាក់ចេញនូវសេចក្តីណែនាំលេខ០១ សណន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងសារាចរលេខ០៨ សរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនៃការរៀបចំមុខងារ និងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន។ យោងតាមលទ្ធផលនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងស្មារតីនៃកិច្ចប្រជុំលើកទី៣ របស់គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា(គ.វ.រ.) នាថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៥ រាជរដ្ឋាភិបាលសូមដាក់ចេញនូវសារាចរស្តីពីការកំណត់ និងការអនុវត្តមុខងារនៅតាមក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ (លើកលែងក្រសួងការពារជាតិ និងអង្គភាពដែលទទួលបន្ទុកសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈនៃក្រសួងមហាផ្ទៃ) ដូចខាងក្រោម៖

### ១. ការកំណត់មុខងារតាមវិស័យរបស់ក្រសួង ស្ថាប័ន

ក្រសួង ស្ថាប័ន ត្រូវធ្វើការកំណត់មុខងាររបស់ខ្លួនឱ្យបានច្បាស់លាស់ ដែលជាមុខងារស្នូលតាមវិស័យ និងមុខងាររងនៃមុខងារស្នូលតាមវិស័យដែលក្រសួង ស្ថាប័នទទួលបន្ទុក។ មុខងារស្នូលតាមវិស័យជាបន្តទៅនេះហៅថា **មុខងារស្នូល**។ មុខងាររងនៃមុខងារស្នូលតាមវិស័យ ជាបន្តទៅនេះហៅថា **មុខងាររងនៃមុខងារស្នូល**។

មុខងារស្នូល និងមុខងាររងនៃមុខងារស្នូល គឺជាមូលដ្ឋានផ្តល់សមត្ថកិច្ចដល់ក្រសួង ស្ថាប័នក្នុងការបំពេញមុខងារនិងភារកិច្ច។

ការកំណត់មុខងារស្នូល និងមុខងាររងនៃមុខងារស្នូល ត្រូវអនុវត្តផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

**១.១ មុខងារស្នូលរបស់ក្រសួង ស្ថាប័ន**

មុខងារស្នូលរបស់ក្រសួង ស្ថាប័ន ជាមុខងារដែលត្រូវបានច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងរាជរដ្ឋាភិបាល កំណត់ និងទទួលស្គាល់ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ក្នុងវិស័យណាមួយ។

ការកំណត់មុខងារស្នូលរបស់ក្រសួង ស្ថាប័ន ត្រូវផ្អែកលើ៖

- ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ច្បាប់ស្ដីពីការបង្កើតក្រសួង ស្ថាប័ន
- ច្បាប់ពាក់ព័ន្ធនឹងវិស័យណាមួយដែលក្រសួង ស្ថាប័នទទួលបន្ទុក
- ព្រះរាជក្រឹត្យពាក់ព័ន្ធនឹងការកំណត់សមត្ថកិច្ចដល់ក្រសួង ស្ថាប័ន
- ការសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល។

មុខងារស្នូលរបស់ក្រសួង ស្ថាប័ន ត្រូវកំណត់ឱ្យបានច្បាស់លាស់នៅក្នុងអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន ដើម្បីជាមូលដ្ឋាននៃការកំណត់ជាបន្តនូវមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន។

**១.២ មុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន**

ក្រសួង ស្ថាប័ន ត្រូវកំណត់មុខងាររងនៃមុខងារស្នូលដោយផ្ដើមចេញពីមុខងារស្នូល ដើម្បីឱ្យមានភាពច្បាស់លាស់ក្នុងការអនុវត្តមុខងារដែលជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងជាមូលដ្ឋានសម្រាប់ការកំណត់ជាបន្តនូវរចនាសម្ព័ន្ធអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន ព្រមទាំងភារកិច្ចរបស់អង្គភាពនីមួយៗ។

ការកំណត់មុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ត្រូវផ្អែកលើ៖

- មុខងារស្នូលរបស់ក្រសួង ស្ថាប័ន ជាមូលដ្ឋានគោល
- គោលបំណង វិធានការ និងសកម្មភាពជាយុទ្ធសាស្ត្រ ដែលកំណត់នៅក្នុងក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាល រួមមាន៖ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលនយោបាយជាតិតាមវិស័យ, ផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ, ឯកសារក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលមានសុពលភាពសម្រាប់នីតិកាលទី៧នៃរដ្ឋសភា, គោលនយោបាយអាទិភាព និងវិធានការគន្លឹះទាំងឡាយរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧នៃរដ្ឋសភា
- គោលបំណង វិធានការ និងសកម្មភាពជាយុទ្ធសាស្ត្រទាំងនេះ ត្រូវផ្សារភ្ជាប់ជាមួយឬជាផ្នែកមួយនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ហើយដែលត្រូវរៀបចំនិងកំណត់ជាមុខងាររងនៃមុខងារស្នូល។

**១.៣ ភារកិច្ចរបស់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន**

ការរៀបចំរចនាសម្ព័ន្ធអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន ត្រូវគិតគូរជាមុនអំពីភារកិច្ចដែលអង្គភាពនីមួយៗត្រូវបំពេញ។

ការកំណត់ភារកិច្ចរបស់អង្គភាពទាំងនេះ ត្រូវផ្អែកលើ៖

- មុខងារស្នូលនិងមុខងាររងនៃមុខងារស្នូលដែលជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន

- ក្របខណ្ឌការងារដែលក្រសួង ស្ថាប័នត្រូវបំពេញដើម្បីអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ដែលមានកំណត់ក្នុងចំណុច (២) នៃសារាចរនេះ
- មុខងារគាំទ្រដែលក្រសួង ស្ថាប័នត្រូវបំពេញដើម្បីអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ដែលមានកំណត់ក្នុងចំណុច (៣) នៃសារាចរនេះ
- មុខងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដែលក្រសួង ស្ថាប័នត្រូវបំពេញដើម្បីធានាថាមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ត្រូវបានអនុវត្តនិងសម្រេចនូវសមិទ្ធកម្មតាមការកំណត់របស់រាជរដ្ឋាភិបាល ដែលមានកំណត់ក្នុងចំណុច (៤) នៃសារាចរនេះ។

## ១.៤ ស្ថានភាពផ្សេងៗនៃការកំណត់មុខងារនិងភារកិច្ច

ស្ថានភាពនៃការត្រួតមុខងារនិងដែនសមត្ថកិច្ច អាចកើតមាននៅកម្រិតមុខងារស្នូល មុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន និងភារកិច្ចរបស់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន។ ទន្ទឹមនេះ ស្ថានភាពមួយចំនួនទៀតក៏អាចកើតឡើង រួមមាន៖ ការកំណត់មុខងារថ្មី មុខងារដែលអនុវត្តមិនមានប្រសិទ្ធភាព មុខងារដែលលែងសមស្រប ការផ្ទេរឬប្រតិភូកម្មមុខងារ ជាដើម។

ការពិនិត្យនិងដោះស្រាយស្ថានភាពទាំងនេះ ត្រូវអនុវត្តផ្អែកលើអភិក្រមការងារដូចខាងក្រោម៖

### ១.៤.១ ការត្រួតមុខងារនិងដែនសមត្ថកិច្ចនៅកម្រិតអន្តរក្រសួង ស្ថាប័ន

ក្នុងករណីមានស្ថានភាពនៃការត្រួតគ្នានៃមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរវាងក្រសួង ស្ថាប័ន ក្រសួងមុខងារសាធារណៈត្រូវធ្វើការសម្របសម្រួលរវាងក្រសួង ស្ថាប័ន ដើម្បីពិនិត្យ ពិភាក្សានិងដោះស្រាយរួមគ្នាអំពីបញ្ហាត្រួតគ្នានៃមុខងារទាំងនេះ និងធ្វើរបាយការណ៍អំពីលទ្ធផលឯកភាពគ្នាជូនប្រមុខរាជរដ្ឋាភិបាលជ្រាប និងផ្តល់ការណែនាំបន្ថែមជាយថាហេតុ។

ក្នុងករណីមិនអាចរកបានការឯកភាពគ្នា ក្រសួងមុខងារសាធារណៈត្រូវលើកបញ្ហានៃការត្រួតគ្នានៃមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

### ១.៤.២ ការត្រួតភារកិច្ចនៅកម្រិតក្នុងក្រសួង ស្ថាប័ន

ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកក្នុងការរៀបចំនិងកំណត់ភារកិច្ចដល់អង្គភាពក្រោមឱវាទ ដោយធានាមិនឱ្យមានការត្រួតគ្នានៃភារកិច្ចរបស់អង្គភាព។

ភារកិច្ចរបស់អង្គភាព ត្រូវមានភាពច្បាស់លាស់ និងឆ្លើយតបនឹងការអនុវត្តមុខងារស្នូលនិងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន, ព្រមទាំងក្របខណ្ឌការងារ, មុខងារគាំទ្រ, និងមុខងារតាមដាន ត្រួតពិនិត្យនិងវាយតម្លៃដែលក្រសួង ស្ថាប័នត្រូវបំពេញ ដើម្បីអនុវត្តមុខងារស្នូលនិងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន។

ក្រសួងមុខងារសាធារណៈ ត្រូវពិនិត្យនិងផ្តល់យោបល់ដល់ក្រសួង ស្ថាប័ន អំពីស្ថានភាពត្រួតភារកិច្ចគ្នារបស់អង្គភាពក្រោមឱវាទរបស់ក្រសួង ស្ថាប័ន ដើម្បីធ្វើការកែលម្អឱ្យបានត្រឹមត្រូវនិងសមស្រប។



ф

### ១.៤.៣ ការកំណត់មុខងារថ្មីបន្ថែម

រាជរដ្ឋាភិបាលអាចកំណត់និងផ្តល់មុខងារថ្មីបន្ថែមដល់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន។

ក្រសួង ស្ថាប័ន ត្រូវពិនិត្យការផ្សារភ្ជាប់មុខងារថ្មីនេះជាមួយនឹង៖

- មុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ឬ
- ក្របខណ្ឌការងារដែលក្រសួង ស្ថាប័នត្រូវបំពេញដើម្បីអនុវត្តមុខងារស្នូលនិងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ឬ
- មុខងារគាំទ្រដែលក្រសួង ស្ថាប័នត្រូវបំពេញដើម្បីអនុវត្តមុខងារស្នូលនិងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ឬ
- មុខងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដែលក្រសួង ស្ថាប័នត្រូវបំពេញដើម្បីធានាថាមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ត្រូវបានអនុវត្តនិងសម្រេចនូវសមិទ្ធកម្មតាមការកំណត់របស់រាជរដ្ឋាភិបាល។

មុខងារថ្មីបន្ថែមនេះ អាចត្រូវផ្តល់បន្ថែមដល់អង្គភាពដែលមានស្រាប់ដើម្បីទទួលបន្ទុកអនុវត្ត។

ក្នុងករណីមានមុខងារថ្មីដែលជាមុខងារចាំបាច់ ប៉ុន្តែមិនមានក្រសួង ស្ថាប័នណាមួយទទួលបន្ទុក ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រសួងមុខងារសាធារណៈ ត្រូវលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចក្នុងការប្រគល់មុខងារនេះជូនដល់ក្រសួង ស្ថាប័នណាមួយទទួលបន្ទុកអនុវត្ត។

### ១.៤.៤ មុខងារដែលអនុវត្តមិនមានប្រសិទ្ធភាព

មុខងារដែលត្រូវបានកំណត់និងរៀបចំដោយច្បាស់លាស់ ប៉ុន្តែការអនុវត្តមុខងារនេះមិនមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រសួងមុខងារសាធារណៈ ត្រូវលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចដើម្បីកំណត់និងរៀបចំមុខងារនេះឡើងវិញ ដើម្បីធានាឱ្យការអនុវត្តសម្រេចសមិទ្ធកម្មស្របតាមការកំណត់របស់រាជរដ្ឋាភិបាល។

### ១.៤.៥ មុខងារដែលលែងមានលក្ខណៈសមស្រប

ផ្អែកលើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន មុខងារដែលលែងមានលក្ខណៈសមស្រប ដោយហេតុការផ្លាស់ប្តូរនៃមុខងារស្នូល, មុខងាររងនៃមុខងារស្នូល, គោលនយោបាយ, បច្ចេកវិទ្យា, រចនាសម្ព័ន្ធស្ថាប័ន, ការប្រែប្រួលនៃបរិបទសេដ្ឋកិច្ចសង្គម ជាដើម ក្រសួង ស្ថាប័នត្រូវកែសម្រួល ឬលុបមុខងារនេះចេញ រួមទាំងត្រូវធ្វើការកែសម្រួលរចនាសម្ព័ន្ធអង្គភាព និងមុខងារនិងភារកិច្ចដែលពាក់ព័ន្ធ។

### ១.៤.៦ មុខងារដែលត្រូវប្រគល់ទៅឱ្យក្រសួង ស្ថាប័នផ្សេង

ចំពោះស្ថានភាពដែលក្រសួង ស្ថាប័នកត់សម្គាល់ថា មុខងារដែលក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្ត អាចត្រូវអនុវត្តដោយក្រសួង ស្ថាប័នផ្សេងមានប្រសិទ្ធភាពខ្ពស់ជាង ក្រសួង ស្ថាប័នអាចស្នើសុំរាជរដ្ឋាភិបាល តាមរយៈក្រសួងមុខងារសាធារណៈ ដើម្បីប្រគល់មុខងារនេះដល់ក្រសួង ស្ថាប័នផ្សេងឱ្យទទួលបន្ទុក។

**១.៤.៧ មុខងារដែលត្រូវបានផ្ទេរ ឬប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ**

មុខងារដែលត្រូវបានផ្ទេរ ឬប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដោយរាជរដ្ឋាភិបាលឬការសម្រេចរបស់ក្រសួង ស្ថាប័ន ក្រសួង ស្ថាប័នសាមីត្រូវធ្វើការពិនិត្យឡើងវិញ ដើម្បីកំណត់និងរៀបចំមុខងារស្នូល, មុខងាររងនៃមុខងារស្នូលរបស់ខ្លួន ព្រមទាំងភារកិច្ចរបស់អង្គភាពក្រោមឱវាទឱ្យបានសមស្រប។

**២. ក្របខណ្ឌការងារសម្រាប់ការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល**

ក្រសួង ស្ថាប័ន ត្រូវពិនិត្យ រៀបចំ និងកំណត់ក្របខណ្ឌការងារឱ្យបានច្បាស់លាស់ ដើម្បីជាមូលដ្ឋាននៃការរៀបចំរចនាសម្ព័ន្ធអង្គភាព, យន្តការស្ថាប័ន, និងប្រព័ន្ធការងារឬវិធីសាស្ត្របំពេញការងារសមស្របផ្សេងៗ ដើម្បីធានាការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័នឱ្យមានប្រសិទ្ធភាព។

ក្របខណ្ឌការងារដែលក្រសួង ស្ថាប័ន ត្រូវបំពេញមានដូចខាងក្រោម៖

**២.១ ក្របខណ្ឌគោលនយោបាយ**

ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកលើក្របខណ្ឌការងារនៃការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន រួមទាំងការបំពេញការងារលើការរៀបចំផែនការយុទ្ធសាស្ត្រ, ក្របខណ្ឌគតិយុត្តនៃការអនុវត្តគោលនយោបាយ, ការស្រាវជ្រាវនិងព្យាករណ៍ផ្នែកគោលនយោបាយ, ការវាយតម្លៃការអនុវត្តគោលនយោបាយ, ការសម្របសម្រួលផ្នែកគោលនយោបាយ និងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីធានាសង្គតិភាព និងសុខដុមនីយកម្មក្នុងការអនុវត្តគោលនយោបាយ។

ក្របខណ្ឌគោលនយោបាយនេះ ត្រូវកំណត់ឱ្យបានជាក់លាក់ដើម្បីតម្រង់ទិស និងកំណត់មូលដ្ឋាននៃវិធានការនិងសកម្មភាពរបស់ក្រសួង ស្ថាប័ន ដើម្បីសម្រេចសមិទ្ធកម្មក្នុងវិស័យ។

មុខងារផ្នែកក្របខណ្ឌគោលនយោបាយអាចត្រូវបំពេញដោយក្រសួង ស្ថាប័ន និងរចនាសម្ព័ន្ធអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន, យន្តការអន្តរស្ថាប័ន ឬយន្តការការងារណាមួយរបស់រាជរដ្ឋាភិបាល។

**២.២ ក្របខណ្ឌបញ្ញត្តិកម្ម**

ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកលើក្របខណ្ឌការងារបញ្ញត្តិកម្មពាក់ព័ន្ធនឹងការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន រួមមាន ការកំណត់បែបបទ, វិធីសាស្ត្រ, ការកំណត់និយាម/ស្តង់ដា, ការកំណត់របបគតិយុត្តនៃការធ្វើសកម្មភាពរបស់បុគ្គល, ការផ្តល់សេវា, ការផ្តល់លិខិតអនុញ្ញាត, ការផ្តល់អាជ្ញាបណ្ណ, ការផ្តល់វិញ្ញាបនបត្រ និងការធានាអនុលោមភាពនៃនិយាម/ស្តង់ដា ជាដើម។

ក្របខណ្ឌបញ្ញត្តិកម្មនេះ គឺដើម្បីធាននានូវការអនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់រូបវន្តបុគ្គល នីតិបុគ្គល និងស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងការការពារនិងថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចនៃការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន។

មុខងារផ្នែកក្របខណ្ឌបញ្ញត្តិកម្ម អាចត្រូវបំពេញដោយក្រសួង ស្ថាប័ន និងរចនាសម្ព័ន្ធអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន, និយ័តករ, ស្ថាប័នវិជ្ជាជីវៈ, យន្តការអន្តរស្ថាប័ន ឬយន្តការការងារណាមួយរបស់រាជរដ្ឋាភិបាល។

## ២.៣ ក្របខណ្ឌសម្របសម្រួល

ផ្អែកលើអភិក្រម **"ជវភាពនៃប្រព័ន្ធតួអង្គតែមួយ"** ការសម្របសម្រួលនិងការគាំទ្រគ្នាក្នុងរដ្ឋបាលសាធារណៈ ជាការចាំបាច់ដើម្បីធានាបាននូវការសម្រេចសមិទ្ធកម្មឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជន។

ក្រសួង ស្ថាប័ន ត្រូវបំពេញការងារក្នុងក្របខណ្ឌសម្របសម្រួលនៅកម្រិតអន្តរក្រសួង ស្ថាប័ន និងនៅក្នុងក្រសួង ស្ថាប័នសាមី។ ការសម្របសម្រួលនេះផ្តោតលើការធ្វើសុខដុមនីយកម្ម ការធានាសង្គតិភាព និងការធានាភាពប្រទាក់ក្រឡានិងគាំទ្រគ្នា លើក្របខណ្ឌគោលនយោបាយ វិធានការ សកម្មភាព ព្រមទាំងការចាត់ចែងនិងប្រើប្រាស់ធនធានមនុស្ស និងថវិកា សំដៅសម្រេចនូវគោលដៅរួមរបស់រាជរដ្ឋាភិបាល។

នៅកម្រិតរាជរដ្ឋាភិបាលនិងអន្តរក្រសួង ស្ថាប័ន ក្រសួង ស្ថាប័នអាចមានតួនាទីក្នុងការដឹកនាំឬចូលរួមគាំទ្រឬផ្តល់កិច្ចសហការ ដើម្បីអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ឬអនុវត្តបេសកកម្ម/មុខងារដែលដាក់ចេញដោយរាជរដ្ឋាភិបាល។

ទន្ទឹមនេះ ក្រសួង ស្ថាប័នក៏ត្រូវធានានូវការដឹកនាំសម្របសម្រួលការបំពេញភារកិច្ចរបស់អង្គភាពក្រោមឱវាទដើម្បីធានាបាននូវការសម្រេចសមិទ្ធកម្មក្នុងការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន។

## ២.៤ ក្របខណ្ឌផ្តល់សេវា

ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកលើក្របខណ្ឌការងារនៃការផ្តល់សេវាដល់ប្រជាជនពាក់ព័ន្ធនឹងការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ខ្លួន រួមមាន ការផ្គត់ផ្គង់/ការផ្តល់ផលិតផលឬសេវាដល់អតិថិជន/អ្នកប្រើប្រាស់សេវា ទាំងក្នុង និងក្រៅក្រសួង ស្ថាប័ន។

ជាធម្មតា ការផ្តល់សេវាសាធារណៈត្រូវអនុវត្តដោយអង្គភាពដែលស្ថិតក្រោមឱវាទឬអាណាព្យាបាលរបស់ក្រសួង ស្ថាប័ន ដែលអាចជា អង្គភាពក្រោមឱវាទផ្ទាល់ គ្រឹះស្ថានសាធារណៈរដ្ឋបាល គ្រឹះស្ថានដែលមានស្វ័យភាព ទីភ្នាក់ងារប្រតិបត្តិការពិសេស មន្ទីររាជធានី ខេត្ត ការិយាល័យក្រុង ស្រុក ខណ្ឌ ការិយាល័យច្រកចេញចូលតែមួយ ឬអង្គភាពផ្តល់សេវាក្រៅក្រសួង ស្ថាប័ន ជាអាទិ៍។

រចនាសម្ព័ន្ធអង្គភាព ត្រូវផ្តល់ភាពងាយស្រួលក្នុងការទទួលយកសេវា ហើយអង្គភាពទាំងនេះត្រូវទទួលបានការផ្តល់នូវសិទ្ធិអំណាចនិងប្រភពធនធានសមស្រប ដើម្បីអាចធានាបាននូវការផ្តល់សេវាប្រកបដោយគុណភាព ព្រមទាំងឆ្លើយតបនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវា។

## ៣. ការគាំទ្រការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល

ក្រសួង ស្ថាប័ន ត្រូវផ្តល់ការគាំទ្រដល់ការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល របស់ក្រសួង ស្ថាប័ន។

ការផ្តល់ការគាំទ្រនេះ ជាការបំពេញមុខងារគាំទ្រដែលក្រសួង ស្ថាប័នត្រូវរៀបចំនិងអនុវត្តឱ្យមានប្រសិទ្ធភាព រួមមាន៖ ការរៀបចំដំណើរការផ្នែករដ្ឋបាលនិងហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស, ការគ្រប់គ្រងនិងចាត់ចែងហិរញ្ញវត្ថុសាធារណៈ, ផែនការនិងស្ថិតិ, និងការរៀបចំនិងអនុវត្តប្រព័ន្ធសវនកម្មផ្ទៃក្នុង។

ដើម្បីធានាសង្គតិភាព និងស្តង់ដារួមសម្រាប់គ្រប់ក្រសួង ស្ថាប័ន ការកំណត់ភារកិច្ចរបស់អង្គភាពដែលបំពេញមុខងារគាំទ្រ និងការកំណត់មុខតំណែងមន្ត្រីអនុវត្តមុខងារគាំទ្រ ត្រូវទទួលបន្ទុករៀបចំដោយក្រសួង ស្ថាប័ន ដូចខាងក្រោម ៖

- មុខងាររដ្ឋបាល និងធនធានមនុស្ស ត្រូវទទួលបន្ទុករៀបចំដោយក្រសួងមុខងារសាធារណៈ
- មុខងារហិរញ្ញវត្ថុ និងសវនកម្មផ្ទៃក្នុង ត្រូវទទួលបន្ទុករៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មុខងារផែនការនិងស្ថិតិ ត្រូវទទួលបន្ទុករៀបចំដោយក្រសួងផែនការ។

ក្រសួង ស្ថាប័នទទួលបន្ទុក ត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការកំណត់ភារកិច្ចរបស់អង្គភាព និងមុខតំណែងមន្ត្រីអនុវត្តមុខងារគាំទ្រ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ អាចកំណត់ភារកិច្ច និងមុខតំណែងមន្ត្រីបន្ថែម សម្រាប់ការអនុវត្តមុខងារគាំទ្រផ្អែកលើស្ថានភាពនិងវិសេសភាពនៃក្រសួង ស្ថាប័ន ដោយត្រូវពិគ្រោះយោបល់ជាមួយក្រសួងទទួលបន្ទុកខាងលើ។

ភារកិច្ចរបស់អង្គភាពដែលបំពេញមុខងារគាំទ្រផ្សេងទៀត ព្រមទាំងការកំណត់មុខតំណែងមន្ត្រីអនុវត្តមុខងារគាំទ្រទាំងនោះ ត្រូវអនុវត្តផ្អែកលើការសម្រេចរបស់គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។

ភារកិច្ចរបស់អង្គភាពបំពេញមុខងារគាំទ្រ និងមុខតំណែងមន្ត្រី ត្រូវកំណត់ដោយអនុក្រឹត្យ។

## ៤. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល

ក្រសួង ស្ថាប័ន ត្រូវរៀបចំឱ្យមានប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងផ្តល់ការគាំទ្រ និងសម្របសម្រួលនានា ដើម្បីធានានូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល។

ការរៀបចំប្រព័ន្ធនេះ ត្រូវផ្សារភ្ជាប់ជាមួយៈ

- ក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល
- សូចនាករសមិទ្ធកម្មក្នុងក្របខណ្ឌនៃការអនុវត្តថវិកាកម្មវិធី
- កិច្ចព្រមព្រៀងសមិទ្ធកម្មរវាងក្រសួង ស្ថាប័នសាមី ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កិច្ចព្រមព្រៀងសមិទ្ធកម្មរវាងប្រធានស្ថាប័ន ជាមួយអង្គភាពក្រោមឱវាទ។

ក្នុងន័យនេះ ក្រសួង ស្ថាប័នត្រូវទទួលខុសត្រូវនិងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល លើសមិទ្ធកម្មក្នុងការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ខ្លួន។ ក្រសួង ស្ថាប័ន ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពការងាររបស់ខ្លួន និងសមិទ្ធកម្មសម្រេចបានធៀបនឹងសូចនាករសមិទ្ធកម្មកំណត់ដោយរាជរដ្ឋាភិបាល។

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនេះ ក៏នឹងជួយដល់ក្រសួង ស្ថាប័ន និងរាជរដ្ឋាភិបាល ក្នុងការពិនិត្យនិងកំណត់ការបែងចែកនិងការប្រើប្រាស់ធនធានមនុស្ស និងថវិកា ព្រមទាំងការរៀបចំយន្តការការងារឱ្យបានសមស្របដើម្បីលើកកម្ពស់សមិទ្ធកម្មកាន់តែប្រសើរ។



៥

## ៥. មុខងារនិងការរៀបចំរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង ស្ថាប័ន ត្រូវអនុវត្តផ្អែកលើមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន, ក្របខណ្ឌការងារសម្រាប់ការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល, មុខងារគាំទ្រ, ព្រមទាំងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល។

ក្នុងន័យនេះ ការរៀបចំរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នត្រូវគិតគូរឈរលើគោលការណ៍ដូចខាងក្រោម៖

### ៥.១ អភិក្រមនៃការរៀបចំរចនាសម្ព័ន្ធ

នៅក្នុងការរៀបចំរចនាសម្ព័ន្ធអង្គភាព ក្រសួង ស្ថាប័ន ត្រូវធានាឱ្យបាននូវការគោរពអភិក្រមការងារដូចខាងក្រោម៖

- ការរៀបចំរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នឱ្យរៀបរយ ដោយធានាឱ្យបាននូវការអនុវត្តមុខងារពិតប្រាកដ ព្រមទាំងអភិក្រមនិងលំហូរការងារក្នុង និងក្រៅក្រសួង ស្ថាប័នឱ្យមានប្រសិទ្ធភាពខ្ពស់, កាន់តែសាមញ្ញ, ប្រើពេលវេលាកាន់តែឆាប់រហ័ស, ចំណាយធនធានថវិកាទាបជាងមុន, និងប្រើប្រាស់ធនធានមនុស្សអស់សក្តានុពល
- ការពង្រឹងរចនាសម្ព័ន្ធស្ថាប័នជាជាងពង្រីករចនាសម្ព័ន្ធស្ថាប័ន ដែលនាំឱ្យប៉ះពាល់ដល់បន្ទុកថវិកា និងបន្ទុកបុគ្គលិក ដោយត្រូវពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធទាំងមូលនិងលំហូរការងារជារួមរបស់ក្រសួង ស្ថាប័ន។

### ៥.២ ការរៀបចំរចនាសម្ព័ន្ធដោយផ្សារភ្ជាប់ជាមួយនឹងការអនុវត្តមុខងារ

ក្រសួង ស្ថាប័ន ត្រូវពិនិត្យ និងរៀបចំរចនាសម្ព័ន្ធអង្គភាពឱ្យមានដំណើរការប្រកបដោយប្រសិទ្ធភាពខ្ពស់ដោយផ្អែកលើ៖

- ការឆ្លើយតបនឹងមុខងារនិងទំហំការងារ
- ការផ្តល់មុខងារបន្ថែមដល់អង្គភាពដែលមានស្រាប់ ជាជាងការបង្កើតអង្គភាពថ្មីឱ្យទទួលបន្ទុក ឬដំឡើងកម្រិតអង្គភាពដែលមានស្រាប់
- ការលុបអង្គភាពដែលមានភារកិច្ចមិនស្របនឹងមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល
- ការច្របាច់បញ្ចូលគ្នានូវរចនាសម្ព័ន្ធដែលបំពេញភារកិច្ចដូចគ្នា ឬអង្គភាពដែលមិនមានដំណើរការឬដំណើរការមិនមានប្រសិទ្ធភាព ដោយពិនិត្យទាំងក្នុងក្របខណ្ឌក្រសួង ស្ថាប័ន និងយន្តការការងារអន្តរក្រសួង ស្ថាប័ន ដែលក្រសួង ស្ថាប័នទទួលបន្ទុក
- ការប្រើប្រាស់រចនាសម្ព័ន្ធអង្គភាពរបស់ក្រសួង ស្ថាប័ន ដើម្បីគាំទ្រដល់យន្តការការងារអន្តរក្រសួង ស្ថាប័ន ដែលទទួលបន្ទុកអនុវត្តដឹកនាំនិងសម្របសម្រួលការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ជាជាងការបង្កើតរចនាសម្ព័ន្ធថ្មីដោយឡែក ដើម្បីគាំទ្រដល់យន្តការការងារអន្តរក្រសួង ស្ថាប័ន។

### ៥.២.១ ការរៀបចំរចនាសម្ព័ន្ធអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល

ការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល ត្រូវគិតគូរផ្អែកលើក្របខណ្ឌការងារ រួមមាន ក្របខណ្ឌគោលនយោបាយ, ក្របខណ្ឌបញ្ញត្តិកម្ម, ក្របខណ្ឌសម្របសម្រួល, ក្របខណ្ឌផ្តល់សេវា និងការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

ការរៀបចំរចនាសម្ព័ន្ធឬយន្តការការងារ ក្នុងក្របខណ្ឌការងារដើម្បីអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល ត្រូវឆ្លើយតបនឹងទំហំការងារ ព្រមទាំងធានាបាននូវប្រសិទ្ធភាពការងារខ្ពស់។

ការរៀបចំរចនាសម្ព័ន្ធនិងយន្តការការងារ ត្រូវគិតគូរផ្អែកលើ៖

- រចនាសម្ព័ន្ធក្នុងកម្រិតអគ្គនាយកដ្ឋាន នាយកដ្ឋាន ឬក្រោមនាយកដ្ឋាន ឱ្យឆ្លើយតបនឹងទំហំនៃការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល
- ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការបំពេញការងារក្នុងក្របខណ្ឌគោលនយោបាយ, ក្របខណ្ឌបញ្ញត្តិកម្ម, ក្របខណ្ឌសម្របសម្រួល, ក្របខណ្ឌផ្តល់សេវា និងការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- ការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល ដោយប្រើប្រាស់យន្តការ រួមមាន យន្តការអន្តរក្រសួង គ្រឹះស្ថាន ក្រុមការងារបច្ចេកទេស គណៈកម្មការ និងយន្តការការងារសមស្របផ្សេងទៀត
- ការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល ដែលអាចប្រើប្រាស់សមត្ថភាពពីខាងក្រៅ។

### ៥.២.២ ការរៀបចំរចនាសម្ព័ន្ធដើម្បីអនុវត្តមុខងារគាំទ្រ

ក្រសួង ស្ថាប័ន ត្រូវរៀបចំរចនាសម្ព័ន្ធដើម្បីអនុវត្តមុខងារគាំទ្រដល់មុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ដូចខាងក្រោម៖

- រចនាសម្ព័ន្ធត្រូវរៀបចំឱ្យបានសមស្របទៅតាមទំហំនិងវិសេសភាពនៃការងាររបស់ក្រសួង ស្ថាប័ននីមួយៗ
- ក្រសួង ស្ថាប័នក៏អាចប្រើប្រាស់យន្តការក្រៅក្រសួង ស្ថាប័ន ដើម្បីបំពេញមុខងារគាំទ្រ ក្នុងករណីដែលការប្រើប្រាស់បែបនេះអាចសម្រេចបានសមិទ្ធកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយប្រើពេលវេលាតិច និងចំណាយទាបជាងការរៀបចំឱ្យមានរចនាសម្ព័ន្ធអង្គភាពនៅក្នុងក្រសួង ស្ថាប័ន ព្រមទាំងមិនបង្កើតបន្ទុកដែលមិនចាំបាច់ជាលក្ខណៈអចិន្ត្រៃយ៍។

### ៥.២.៣ ការទទួលខុសត្រូវ និងគណនេយ្យភាព

ក្រសួង ស្ថាប័ន ត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីការទទួលខុសត្រូវនិងគណនេយ្យភាពរបស់មន្ត្រីដែលទទួលបន្ទុកបំពេញតួនាទីនិងភារកិច្ចនៅក្នុងរចនាសម្ព័ន្ធអង្គភាពរបស់ក្រសួង ស្ថាប័ន ដែលធានានូវការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន។

## ៦. មុខងារនិងការប្រើប្រាស់ធនធានមនុស្ស

ក្រសួង ស្ថាប័ន ត្រូវកំណត់មុខតំណែងនិងប្រើប្រាស់មុខតំណែងជាក់លាក់ ដើម្បីរៀបចំនិងអនុវត្តផែនការនៃការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួន។

មុខងារស្នូល និងមុខងាររងនៃមុខងារស្នូល, ក្របខណ្ឌការងារក្នុងការអនុវត្តមុខងារស្នូលនិងមុខងាររងនៃមុខងារស្នូល, មុខងារគាំទ្រ ព្រមទាំងមុខងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់មុខតំណែង ការពិពណ៌នាមុខតំណែង និងគុណវុឌ្ឍិនៃមុខតំណែងមន្ត្រី។

ប្រសិនបើក្រសួង ស្ថាប័នមិនបានកំណត់មុខតំណែងជាក់លាក់ ឆ្លើយតបនឹងតម្រូវការនៃមុខងារ និងក្របខណ្ឌការងារ ក្រសួង ស្ថាប័នមិនត្រូវបានអនុញ្ញាតឱ្យជ្រើសរើសមន្ត្រីថ្មីបន្ថែមទៀតឡើយ។

## ៧. មុខងារនិងការប្រើប្រាស់ថវិកា

ការវិភាជ និងប្រើប្រាស់ថវិកា ត្រូវឆ្លើយតបនឹងការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល ដោយសម្រេចឱ្យបាននូវសូចនាករសមិទ្ធកម្មដែលបានកំណត់។

ការប្រើប្រាស់ថវិកា ដើម្បីលើកទឹកចិត្តគាំទ្រសមិទ្ធកម្មនៅតាមក្រសួង ស្ថាប័ន ត្រូវផ្អែកលើមូលដ្ឋាននៃសូចនាករសមិទ្ធកម្ម ដែលត្រូវកំណត់ឆ្លើយតបនឹងការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន។

## ៨. ការផ្តល់ការគាំទ្រ

ក្រសួងមុខងារសាធារណៈ ត្រូវផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័នក្នុងការកំណត់ និងការអនុវត្តមុខងារ និងការរៀបចំរចនាសម្ព័ន្ធស្របតាមខ្លឹមសារនៃសារាចរនេះ។

ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ០៧១.......................

ថ្ងៃ.....១៣.......... ខែ.......... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.១០.... ខែ.......... ឆ្នាំ២០២៥

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ២០១ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុងកំពង់សោម នៃខេត្តព្រះសីហនុ
- យោងលិខិតលេខ១០២៧/២១ គ.វ.ក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតស្បែកជើង កាបូប និងខ្សែក្រវាត់គ្រប់ប្រភេទ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥ របស់ក្រុមហ៊ុន ខេមបូឌាន ឈី មីង ស៊ីង ជា ជូ យ៉ុង គីន ឯ.ក

**សម្រេច**

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូឌាន ឈី មីង ស៊ីង ជា ជូ យ៉ុង គីន ឯ.ក (**CAMBODIAN QI MING XING JIA JU YONG PIN CO., LTD.**) តំណាងដោយលោក **GUO, HONGFEI** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EJ3779882** ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១ បង្កើតរោងចក្រផលិតស្បែកជើង កាបូប និងខ្សែក្រវាត់គ្រប់ប្រភេទ ដែលមានទីតាំងស្ថិតនៅភូមិអូរចំណារ សង្កាត់អូរឧកញ៉ាហេង ក្រុងកំពង់សោម ខេត្តព្រះសីហនុ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| ១-ស្បែកជើង | ១៥២០ |
| ២-កាបូប | ១៥១២ |
| ៣-ខ្សែក្រវាត់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតស្បែកជើង កាបូប និងខ្សែក្រវាត់គ្រប់ប្រភេទ ខេមបូឌាន ឈី មីង ស៊ីង ជា ជូ យ៉ុង ភីន ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ២៤៧ ឧវបន.កឧ.ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**បណ្ឌិត ទឹម ស៊ីនី**

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -ខុទ្ទកាល័យរដ្ឋមន្ត្រី
- -សាលាខេត្តព្រះសីហនុ
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ
- -រដ្ឋបាលក្រុងកំពង់សោម

  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ០៧៤២ ឧ.វ.ប.ន.ក.ស.ក.ប្រក......

ថ្ងៃ ចន្ទ ១៣ កើត ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២៥

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ៤៧៦៥/១៩ គ.វ.ក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផ្គុំដំឡើងអំពូលភ្លើងគ្រប់ប្រភេទ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងលិខិតលេខ៥២៧៨/២៤ គ.វ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការប្តូរទីតាំងរោងចក្រ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្តូរវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ របស់ក្រុមហ៊ុន នីងបូ ដុងស៊ីង (ខេមបូឌា) អេឡិកទ្រីក ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន នីងបូ ដុងស៊ីង (ខេមបូឌា) អេឡិកទ្រីក ឯ.ក (**NINGBO DONGXING (CAMBODIA) ELECTRIC CO., LTD.**) តំណាងដោយលោក **ZHANG, XUNHAO** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EJ3030016** ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ បង្កើតរោងចក្រផ្គុំដំឡើងអំពូលភ្លើងគ្រប់ប្រភេទ ដែលមានទីតាំងស្ថិតនៅភូមិព្រៃតាភេម ឃុំពោធិអង្គ្រង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| អំពូលភ្លើងគ្រប់ប្រភេទ (ផ្គុំដំឡើង) | ២៧៤០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ **" រោងចក្រផ្គុំដំឡើងអំពូលភ្លើងគ្រប់ប្រភេទ នីងបូ ដុងស៊ីង (ខេមបូឌា) អេឡិកទ្រីក ឯ.ក "**

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ០៣៦ ឧវបន.កឧ.ប្រក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២៣ និងលិខិតលេខ ៤៣៥ ឧវបន.កឧ.លស ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥ ស្តីពីការប្តូរទីតាំងរោងចក្រ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**បណ្ឌិត ទឹម ស៊ីនី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-ខុទ្ទកាល័យរដ្ឋមន្ត្រី
-សាលាខេត្តកំពង់ស្ពឺ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ
-រដ្ឋបាលស្រុកបរសេដ្ឋ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី